# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ២៦៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតមូលនិធិស្រាវជ្រាវជាតិជាបរធនបាលកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០២០/១០៧៣ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៤/១០២៦ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីបរធនបាលកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតមូលនិធិស្រាវជ្រាវជាតិ សរសេរជាអក្សរកាត់ថា**ម.ស.ជ.**និងជាភាសាអង់គ្លេសថា National Research Foundation សរសេរជាអក្សរកាត់ថា NRF ជាបរធនបាលកិច្ចសាធារណៈ ដើម្បីកៀរគរ គ្រប់គ្រង និងចាត់ចែងបរធនពីប្រភពស្របច្បាប់នានា សម្រាប់គាំទ្រដល់ការស្រាវជ្រាវនិងអភិវឌ្ឍន៍របស់គ្រឹះស្ថានស្រាវជ្រាវសាធារណៈនិងឯកជន ស្ថាប័នដៃគូ និងស្ថាប័នស្រាវជ្រាវផ្សេងទៀត សំដៅជំរុញការអភិវឌ្ឍប្រព័ន្ធនវានុវត្តន៍ជាតិប្រកបដោយប្រសិទ្ធភាព បរិយាបន្ន និងចីរភាព។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការកៀរគរ ការគ្រប់គ្រង និងការចាត់ចែងមូលនិធិស្រាវជ្រាវជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ការស្រាវជ្រាវនិងអភិវឌ្ឍន៍** សំដៅដល់កិច្ចការដែលមានលក្ខណៈជាប្រព័ន្ធនិងភាពច្នៃប្រឌិតសម្រាប់បង្កើនសន្និធិចំណេះដឹង និងសម្រាប់បង្កើតសមិទ្ធផលដូចជាបច្ចេកវិទ្យា ផលិតផល និងសេវាកម្មថ្មីៗ ដើម្បីជំរុញនវានុវត្តន៍
- **បរធន** សំដៅដល់ទ្រព្យសម្បត្តិឬមូលនិធិ ដែលបានផ្ទេរឱ្យបរធនបាលនៃ**ម.ស.ជ.**ធ្វើការគ្រប់គ្រងនិងចាត់ចែងសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលកំណត់ដោយអនុក្រឹត្យនេះ
- **បរធនបាល** សំដៅដល់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**
- **បរធនបាលទាយក** សំដៅដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- **បរធនបាលកិច្ច** សំដៅដល់ការគ្រប់គ្រងនិងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយកនិង/ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ចសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ស្របតាមអនុក្រឹត្យនេះ
- **អត្ថគាហកៈ** សំដៅដល់គ្រឹះស្ថានស្រាវជ្រាវសាធារណៈនិងឯកជន ស្ថាប័នដៃគូ និងស្ថាប័នស្រាវជ្រាវផ្សេងទៀត ដែលជាអ្នកទទួលផលប្រយោជន៍ពីបរធនបាលកិច្ចនេះ។

## ជំពូកទី២

## សមាសភាព ភារកិច្ច និងការប្រព្រឹត្តទៅ

## ផ្នែកទី១

## ក្រុមប្រឹក្សាបរធនបាលនៃម.ស.ជ.

**មាត្រា៤ .-**

បរធនបាលកិច្ចត្រូវបានគ្រប់គ្រងនិងចាត់ចែងបរធនដោយក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**។

**មាត្រា៥ ._**

ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ឌ.**មានសមាសភាពដូចតទៅ៖

- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១រូប សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា១រូប សមាជិក
- តំណាងវិស័យឯកជន២រូប សមាជិក
- នាយកប្រតិបត្តិនៃអង្គភាពប្រតិបត្តិនៃ**ម.ស.ឌ.** សមាជិក។

សមាសភាពជាក់ស្តែងរបស់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ឌ.** ត្រូវទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ប្រធាន**ម.ស.ឌ.**តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នសាមីដែលជាសមាជិក។

សមាជិកក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ឌ.**មានអាណត្តិ៣(បី)ឆ្នាំ និងអាចបន្តទៀតបានតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នសាមី។

សមាជិកក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ឌ.**ដែលជាតំណាងវិស័យឯកជនត្រូវមានគុណវុឌ្ឍិសមស្របជាបរធនបាលរូបវន្តបុគ្គលឯករាជ្យដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ចនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**មាត្រា៦ ._**

ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ឌ.**មានភារកិច្ចដូចខាងក្រោម៖

- កំណត់ទិសដៅនិងក្របខ័ណ្ឌយុទ្ធសាស្ត្រឆ្លើយតបនឹងគោលបំណងនៃ**ម.ស.ឌ.**និងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការមេ ផែនការសកម្មភាព របៀបវារៈស្រាវជ្រាវជាតិដែលបានអនុម័តដោយក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(**ក.ជ.វ.ប.ន.**)
- ពិនិត្យនិងសម្រេចផែនការសកម្មភាព ផែនការថវិកាប្រចាំឆ្នាំ របាយការណ៍ហិរញ្ញវត្ថុ បទបញ្ជាផ្ទៃក្នុង និងផែនការលទ្ធកម្មប្រចាំឆ្នាំនៃ**ម.ស.ឌ.**
- កៀរគរធនធានហិរញ្ញវត្ថុ បច្ចេកទេស និងធនធានមនុស្ស ដើម្បីបម្រើដល់គោលបំណងនៃ**ម.ស.ឌ.**
- កំណត់ការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាពប្រតិបត្តិនៃ**ម.ស.ឌ.**
- អនុម័តគោលការណ៍ណែនាំ ស្តង់ដាប្រតិបត្តិ នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុចាំបាច់នានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងនិងដំណើរការនៃ**ម.ស.ឌ.**ដើម្បីធានាឱ្យបាននូវយន្តការប្រតិតុល្យលើការគ្រប់គ្រង និងស្វ័យភាពរដ្ឋបាលនិងហិរញ្ញវត្ថុ
- រៀបចំរបាយការណ៍ជូន**ក.ជ.វ.ប.ន.**ដើម្បីពិនិត្យ តម្រង់ទិស និងផ្តល់អនុសាសន៍
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៧ ._**

ដំណើរការការងាររបស់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ឌ.**ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងនៃ**ម.ស.ឌ.**។

**មាត្រា៨ ._**

ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ឌ.** ត្រូវរៀបចំកិច្ចប្រជុំយ៉ាងតិច២(ពីរ)ដងក្នុងមួយឆ្នាំឬអាចមានកិច្ចប្រជុំវិសាមញ្ញ តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាបរធនបាល។ ក្នុងករណីចាំបាច់ ប្រធានក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ឌ.**អាចប្រគល់សិទ្ធិឱ្យសមាជិកណាម្នាក់ដឹកនាំកិច្ចប្រជុំជំនួស។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការចូលរួមលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សាបរធនបាល។ ក្នុងករណីអវត្តមានសមាជិករបស់ក្រុមប្រឹក្សាបរធនបាលពុំអាចប្រគល់សិទ្ធិប្រជុំជំនួសបានទេ។

ប្រធានក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**អាចអញ្ជើញតំណាងក្រសួង ស្ថាប័ននានា ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**និងឥស្សរជននានា ដែលមានបទពិសោធក្នុងវិស័យពាក់ព័ន្ធឱ្យចូលរួមប្រជុំដើម្បីផ្តល់មតិយោបល់ ប៉ុន្តែតំណាងទាំងនោះ ពុំមានសិទ្ធិបោះឆ្នោតឡើយ។

**មាត្រា៩ .-**

សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**ត្រូវសម្រេចតាមសំឡេងភាគច្រើនដាច់ខាតនៃសមាជិកទាំងអស់នៃក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**មានឧត្តមានុភាព។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានការចុះហត្ថលេខាពីប្រធានក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**និងត្រូវរក្សាទុកនៅទីស្នាក់ការនៃ**ម.ស.ជ.**។

## ផ្នែកទី២
## អង្គភាពប្រតិបត្តិនៃម.ស.ជ.

**មាត្រា១០ .-**

**ម.ស.ជ.**មានអង្គភាពប្រតិបត្តិមួយដែលអនុវត្តកិច្ចប្រតិបត្តិការប្រចាំថ្ងៃ។

អង្គភាពប្រតិបត្តិនៃ**ម.ស.ជ.**មានតួនាទីគ្រប់គ្រងការអនុវត្តផែនការសកម្មភាពដែលបានសម្រេចដោយក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**ដើម្បីសម្រេចគោលបំណងនៃ**ម.ស.ជ.**។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពប្រតិបត្តិនៃ**ម.ស.ជ.**ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងអាចកែសម្រួលតាមការចាំបាច់។

**មាត្រា១១ .-**

អង្គភាពប្រតិបត្តិនៃ**ម.ស.ជ.**ត្រូវគ្រប់គ្រងដោយនាយកប្រតិបត្តិ១(មួយ)រូប និងអាចមាននាយករងប្រតិបត្តិមួយចំនួនជាជំនួយការតាមការចាំបាច់ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នាយកប្រតិបត្តិត្រូវតែងតាំងនិងបញ្ចប់ពីមុខតំណែងដោយសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**។

នាយករងប្រតិបត្តិត្រូវតែងតាំងនិងបញ្ចប់ពីមុខតំណែងដោយសេចក្តីសម្រេចរបស់នាយកប្រតិបត្តិនៃ**ម.ស.ជ.**ក្រោយពីមានការឯកភាពពីប្រធានក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**។

អង្គភាពប្រតិបត្តិនៃ**ម.ស.ជ.**អាចជ្រើសរើសមន្ត្រីឬបុគ្គលិកកិច្ចសន្យាដែលមានគុណវុឌ្ឍិការងារពាក់ព័ន្ធដើម្បីបំពេញការងារតាមតម្រូវការចាំបាច់និងធានាបានប្រសិទ្ធភាពការងាររបស់ខ្លួន។

**មាត្រា១២ .-**

អង្គភាពប្រតិបត្តិនៃ**ម.ស.ជ.**មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពនៃ**ម.ស.ជ.**ដាក់ជូនក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**
- គ្រប់គ្រងការអនុវត្តផែនការសកម្មភាពនៃ**ម.ស.ជ.**ស្របតាមបទប្បញ្ញត្តិ គោលការណ៍ណែនាំ និងសៀវភៅណែនាំសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលកំណត់ដោយ**ក.ជ.ថ.ប.ន.**

- រៀបចំ បង្កើត និងផ្តល់សេវានិងសកម្មភាពគាំទ្រនានាជូនអគ្គគាហកៈដើម្បីជានាប្រសិទ្ធភាពនៃការអនុវត្តការស្រាវជ្រាវនិងអភិវឌ្ឍន៍
- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងការប្រើប្រាស់ធនធាននៃ**ម.ស.ជ.**
- ផ្តល់ការគាំទ្រនិងពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍពាក់ព័ន្ធ ដែលគាំទ្រដល់ការអនុវត្តកម្មវិធីក្រោមសមត្ថកិច្ចនៃ**ម.ស.ជ.**
- រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាសនិងប្រចាំឆ្នាំនៃ**ម.ស.ជ.**ដាក់ជូនក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**
- សម្របសម្រួលនិងសហការជាមួយគណៈកម្មការស្រាវជ្រាវនិងអភិវឌ្ឍន៍នៃ**ក.ជ.ទ.ប.ន.**ដើម្បីគ្រប់គ្រងការស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌ**ក.ជ.ទ.ប.ន.**
- បំពេញមុខងាររដ្ឋបាល ហិរញ្ញវត្ថុ និងបច្ចេកទេសប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**។

## ផ្នែកទី៣
## រូបសញ្ញានិងត្រានៃម.ស.ជ.

**មាត្រា១៣ .-**

**ម.ស.ជ.**មានរូបសញ្ញានិងត្រាដោយឡែកក្នុងការបំពេញភារកិច្ចរបស់ខ្លួនតាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**។

## ជំពូកទី៣
## ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យនៃម.ស.ជ.

**មាត្រា១៤ .-**

ចំណូលនិងចំណាយសម្រាប់ដំណើរការនៃ**ម.ស.ជ.**ត្រូវគ្រោងក្នុងផែនការថវិកាប្រចាំឆ្នាំនៃ**ម.ស.ជ.**។

ការទូទាត់និងការបើកប្រាក់ ដូចមានកំណត់ក្នុងនីតិវិធីនិងបទបញ្ជាផ្ទៃក្នុងនៃ**ម.ស.ជ.**អាចត្រូវបានផ្តល់សិទ្ធិឱ្យនាយកប្រតិបត្តិនៃអង្គភាពប្រតិបត្តិនៃ**ម.ស.ជ.**តាមការសម្រេចរបស់ក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**។

**មាត្រា១៥ .-**

អង្គភាពប្រតិបត្តិនៃ**ម.ស.ជ.**ចាំបាច់ត្រូវកត់ត្រារាល់ចំណូល ចំណាយ រក្សាទុកនូវរាល់ឯកសារពាក់ព័ន្ធនិងរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមប្រព័ន្ធស្តង់ដាគណនេយ្យកម្ពុជាដើម្បីដាក់ជូនក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**ពិនិត្យនិងសម្រេច។

## ជំពូកទី៤
## ប្រភពបរធន

**មាត្រា១៦ .-**

ប្រភពបរធននៃ**ម.ស.ជ.**បានមកពីថវិកាជាតិ ដៃគូអភិវឌ្ឍ វិស័យឯកជន និងប្រភពស្របច្បាប់ផ្សេងទៀត។

បរធននៃ**ម.ស.ជ.**ត្រូវរក្សាទុកក្នុងគណនីធនាគារនៃ**ម.ស.ជ.** ហើយបរធនបាលត្រូវចាត់ចែងបរធនតាមនីតិវិធីដែលកំណត់ដោយក្រុមប្រឹក្សាបរធនបាលនៃ**ម.ស.ជ.**។

## ជំពូកទី៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៧ .-**

ការគ្រប់គ្រងនិងការប្រើប្រាស់ថវិកាប្រចាំឆ្នាំនៃ**ម.ស.ឌ.**ជាកម្មវត្ថុនៃការធ្វើសវនកម្មប្រចាំឆ្នាំដោយសវនករឯករាជ្យ។

**មាត្រា១៨ .-**

ក្រុមប្រឹក្សាភិបាលនៃ**ម.ស.ឌ.**មានសិទ្ធិបង្កើតអង្គភាពត្រួតពិនិត្យផ្ទៃក្នុង ក្នុងករណីចាំបាច់។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១១ កើត ខែ អស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**ហែម វណ្ណឌី**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ